# កិច្ចតែងការបង្រៀន

- មុខវិជ្ជា៖ វិទ្យាសាស្ត្រ
- ប្រធានបទ៖ ការរស់នៅប្រចាំថ្ងៃ
- ខ្លឹមសារ ៖ ការស្វែងយល់ដោយការសង្កេត
- សកម្មភាពគោល៖ សង្កេត
- ចំណងជើងមេរៀន ៖ «រូបភាពពស់ស្រកាចាស់ »
- ថ្នាក់កម្រិត ខ្ពស់
- រយៈពេល ៣០នាទី

## ១.វត្ថុបំណង

- វិជ្ជាសម្បទា៖ កុមារប្រាប់បានពីឈ្មោះ រូបរាង ពណ៌សម្បុរផ្នែកផ្សេងៗ ផលប្រយោជន៍ ផលប៉ះពាល់របស់ពស់ស្រកាចាស់បានត្រឹមត្រូវតាមរយៈការណែនាំរបស់គ្រូ។
- បំណិនសម្បទា៖ដឹងបានពីឈ្មោះ រូបរាង ពណ៌សម្បុរផ្នែកផ្សេងៗ ផលប្រយោជន៍ ផលប៉ះពាល់របស់ពស់ស្រកាចាស់បានត្រឹមត្រូវតាមរយៈការសង្កេតរូបភាពផ្ទាល់។
- ចរិយាសម្បទា៖ បណ្តុះស្មារតីកុមាររវចចេះមានបម្រុងប្រយ័ត្ន ឈ្លាសវៃ រហ័សរហួន

## ២.សម្ភារ:ឧបទេស

- សម្ភារ:គ្រូ៖ ផ្ទាំងរូបភាពសត្វពស់ ដីឥដ្ឋ
- សម្ភារ:កុមារ៖ ដីឥដ្ឋ
- ការរៀបចំ៖ អង្គុយរាងអក្សរអ៊ុយ

## ៣.ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| <br><br>-រាប់ចំនួនកុមារ<br>-ពិនិត្យក្រចកដៃនិងសម្លៀកបំពាក់<br>-កូនៗអង្គុយឱ្យត្រង់ខ្លួន<br>-នាំកុមារច្រៀងចម្រៀង «មកទីនេះ»<br><br><br>-តើកាលពីថ្ងៃមុនអ្នកគ្រូនាំកូនសង្កេតអ្វី? | ជំហានទី១<br>លំនឹងថ្នាក់<br>-ពិនិត្យអវត្តមាន<br>-ពិនិត្យអនាម័យ<br><br>-៣ផ្ទឹងសណ្តាប់ធ្នាប់<br>-ប្រមូលអារម្មណ៍<br><br>ជំហានទី២<br>+រំឮកមេរៀនចាស់<br>-សត្វពស់វែករនាម | <br><br>-នៅស្ងៀម<br>-ដាក់ជូនគ្រូពិនិត្យ<br><br>-អង្គុយត្រង់ខ្លួនស្តាប់គ្រូ<br>-ច្រៀងទាំងអស់គ្នា<br><br><br>-ឆ្លើយ |

| | | |
|---|---|---|
| **-តើសត្វពស់វែករនាមមានរូបរាងយ៉ាងមិចដែរកូន?** | -ពណ៌ប្រផេះ | -ឆ្លើយ |
| | +ទំនាក់ទំនងមេរៀនថ្មី | |
| **-ខែនេះមានភ្លៀងធ្លាក់ហើយចឹងកូនដឹងទេថាវាសម្បូរសត្វអ្វីចេញមក?** | -សត្វពស់ មូស | -ឆ្លើយរៀបរាប់ |
| | ជំហានទី៣<br>មេរៀនថ្មី៖សង្កេត « រូបភាពពស់ស្រកាចាស់» | |
| -ពេលមកតាមផ្លូវអ្នកបានរើសបានថង់ខ្មៅមួយតែមិនដឹងថាក្នុងហ្នឹងមានអ្វីទេ កូនចង់ឃើញអត់កូន? | -ពញ្ញាក់អារម្មណ៍ | -ឆ្លើយ |
| -បង្ហាញរូបភាព | -បង្ហាញសម្ភារៈ<br> | -សង្កេត |
| -តើកូនវាមានពណ៌អ្វីដែរកូន? | -ប្រផេះ | -ឆ្លើយ |
| -ឥឡូវកូនមើលនេះគេហៅថាអ្វីដែរកូន? | -ក្បាល | -ឆ្លើយ |
| -បន្ទាប់ពីក្បាលវាគេហៅថាអ្វីកូន? | -ខ្លួន | -ឆ្លើយ |
| -ចុះនេះវិញកូន? | -កន្ទុយ | |
| -នៅខាងក្បាលកូនឃើញមានអ្វីខ្លះ? | -ភ្នែក មាត់ ច្រមុះ | -ឆ្លើយ<br>-ឆ្លើយ |
| -ខ្លួនពស់ស្រកាចាស់មានរូបរាងស្រដៀងពស់ថ្លាន់ដែរ ព្រោះខ្លួនវាមានក្រឡាៗដូចហូលដែរ | | -ស្តាប់ |
| -តើកូនៗដឹងទេថាពស់នេះស៊ីអ្វីជាអាហារ? | -សត្វល្អិត | -ឆ្លើយ |

| | | |
|---|---|---|
| +ប្រាប់ពីផលប៉ះពាល់ ពស់ស្រកាចាស់មានពិសជាងពស់ទូទៅប៉ុន្តែវាមិនសូវចឹកនៅពេលថ្ងៃទេ កុំឱ្យតែយើងជាន់វា ព្រោះពស់នេះខ្វាក់មាន់ ងងឹតនៅពេលថ្ងៃ ហើយវាសម្បូរនៅខេត្តបាត់ដំបង ពោធិ៍សាត់ សៀមរាប និងខេត្តកំពង់ធំ វារស់នៅតាមជញ្ជាំងស្រូវ និងដីកំពកៗ ។ | +ប្រាប់ពីផលប៉ះពាល់ | -ស្តាប់ |
| +ផលប្រយោជន៍ គឺពស់ស្រកាចាស់ស៊ីសត្វល្អិតជាអាហារ | +ផលប្រយោជន៍ | -ស្តាប់ |
| -ចឹងកូនៗត្រូវចាំថាមិនមែនមានតែពស់ស្រកាចាស់ទេដែលមានពឹសគឺមានពស់ផ្សេងទៀតដែលកូនៗមិនទាន់ស្គាល់ ចឹងប្រសិនកូនឃើញពស់ កូនកុំចាប់វាលេង ហើយទៅដើរឱ្យឆ្ងាយពីវារួចទៅប្រាប់មនុស្សចាស់ឱ្យបានដឹង។ | -ផ្តល់ចំណេះដឹងថ្មី | -ស្តាប់ |
| | ជំហានទី៤<br>+ពង្រឹងចំណេះដឹង | |
| -តើអំបាញ់មិញអ្នកគ្រូបាននាំកូនសង្កេតសត្វអ្វី? | -សង្កេត « រូបភាពពស់ស្រកាចាស់» | -ឆ្លើយ |
| -តើសត្វពស់ស្រកាចាស់រស់នៅខេត្តណាខ្លះ? | -ខេត្តបាត់ដំបង ពោធិ៍សាត់ សៀមរាប និងខេត្តកំពង់ធំ | -ឆ្លើយ |
| | ជំហានទី៥<br>+បណ្តាំផ្ញើ | |
| -ថ្ងៃនេះកូនៗឆ្លាតៗណាស់យកចិត្តទុកដាក់ស្តាប់អ្នកគ្រូគ្រប់ៗគ្នា | -ការលើកសរសើររួម | -ស្តាប់ |

| | | |
|---|---|---|
| -ទៅវិញប្រាប់ប៉ា ម៉ាក់ពីការសង្កេតពស់ថ្ងៃនេះផងណា ឱ្យពួកគាត់បានដឹងផង | ផ្កាំផ្ញើ | -ឆ្លើយចាសបាទ |

ថ្ងៃចន្ទ៦រោចខែជេស្ឋ ឆ្នាំម្សាញ់សប្តស័កព.ស២៥៦៩
ត្រូវនឹងថ្ងៃទី១៦ខែមិថុនា ឆ្នាំ២០២៥
គ្រូបន្ទុកថ្នាក់

មាន សុផា

**បានឃើញនិងឯកភាព**
**នាយិកាសាលា**

អ៊ិច-ណារឿន